# ឧស្សាហកម្មលក់ស្រាបៀរកម្ពុជា
# (BSIC)

## ក្រមស្តីពីការប្រព្រឹត្ត
## សម្រាប់បុគ្គលិកផ្សព្វផ្សាយស្រាបៀរ (BPs)

ឯកសារនេះឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀង ដែលបានធ្វើឡើងដោយសមាជិកនៃឧស្សាកម្មលក់ស្រាបៀរ នៅក្នុងប្រទេសកម្ពុជា។ ឧស្សាហកម្មលក់ស្រាបៀរកម្ពុជា (BSIC) នេះនឹងលើកឡើងពីបញ្ហាសុខភាពនិងសុវត្ថិភាពការងាររបស់បុគ្គលិកផ្សព្វផ្សាយស្រាបៀរ ទៅកាន់សមាជិករបស់ខ្លួន, ម្ចាស់ហាង, អ្នកពិសា ព្រមទាំងនឹងតំណាងឱ្យឧស្សាហកម្មនេះក្នុងកម្រិតជាតិនិងអន្តរជាតិ។

**សេចក្តីថ្លែងបញ្ជាក់ពីគោលបំណង**

ឧស្សាហកម្មលក់ស្រាបៀរកម្ពុជា (BSIC) ទទួលស្គាល់ថាខ្លួនមានការទទួលខុសត្រូវក្នុងការលើកកំពស់លក្ខខណ្ឌសុខភាពនិងលក្ខខណ្ឌការងាររបស់បុគ្គលិកផ្សព្វផ្សាយស្រាបៀរ នៅក្នុងទីផ្សារអតិថិជនកម្ពុជា។ រចនាសម្ព័ន្ធចាត់តាំងរបស់ឧស្សាហកម្មនេះឯកភាពលើបទដ្ឋានឧស្សាហកម្មដូចខាងក្រោម ហើយនឹងប្រើឥទ្ធិពលរបស់ខ្លួន ដើម្បីធានាថាអ្នក ទទួលផលប្រយោជន៍ដទៃទៀត ក៏នឹងអនុវត្តតាមបទដ្ឋានទាំងនេះផងដែរ។ សមាជិកទាំងអស់នៃរចនាសម្ព័ន្ធចាត់តាំង របស់ឧស្សាហកម្មនេះ បានឯកភាពតាមបទដ្ឋានទាំងនេះទាំងអស់គ្នា។

### ទិសដៅ

យើងមានទិសដៅលើកកំពស់សុខភាព, សុវត្ថិភាព និង លក្ខខណ្ឌការងាររបស់បុគ្គលិកផ្សព្វផ្សាយស្រាបៀរ តាមរយៈការកំណត់ចេញជាបទដ្ឋានឧស្សាហកម្ម។

### បទដ្ឋានឧស្សាហកម្ម

*បទដ្ឋានទាំងប្រាំពីរដូចខាងក្រោមគឺជាបទដ្ឋានអប្បបរមា ដែលសមាជិក BSIC បានទទួលស្គាល់ថា ជាបទដ្ឋានសំខាន់ដែលត្រូវតែអនុវត្តតាម សំដៅលើកកំពស់សុខភាព, សុវត្ថិភាព និង លក្ខខណ្ឌការងាររបស់បុគ្គលិកផ្សព្វផ្សាយស្រាបៀរ។*

## 1- ស្ថានភាពនៃការជ្រើសរើស

ស្ថានភាពនៃការជ្រើសរើសបុគ្គលិកផ្សព្វផ្សាយស្រាបៀរ ត្រូវតែអនុវត្តតាមច្បាប់ការងារនៃប្រទេសកម្ពុជា (ឆ្នាំ 1997)។ បុគ្គលិកផ្សព្វផ្សាយស្រាបៀរត្រូវតែមានកិច្ចសន្យាជួលប្រកបដោយតម្លាភាពនិងជាលាយលក្ខណ៍អក្សរមួយ ទោះបីពួកគេត្រូវជួលជាបុគ្គលិករយៈពេលខ្លី, ជាបុគ្គលិកពេញម៉ោងឬជាបុគ្គលិកមិនពេញម៉ោងក្តី។ បុគ្គលិកផ្សព្វផ្សាយស្រាបៀរ នឹងទទួលបាននូវច្បាប់ចម្លងនៃកិច្ចសន្យាជួលនេះមួយច្បាប់។ បុគ្គលិកផ្សព្វផ្សាយស្រាបៀរ នឹងទទួលបាននូវប្រាក់បៀវត្សគោលប្រចាំខែវេរមួយ ហើយជានិច្ចកាលនឹងត្រូវផ្តល់នូវការទូទាត់ទាំងឡាយ ដោយអនុលោមទៅតាមវិធាននិងបទបញ្ញត្តិរបស់ប្រទេសកម្ពុជា។ ប្រព័ន្ធប្រាក់រង្វាន់លើកទឹកចិត្ត អាចត្រូវបង្កើតឡើងបន្ថែមពីលើប្រាក់បៀវត្សគោលនេះ ក៏ប៉ុន្តែ គួរតែត្រូវបង្កើតឡើងនៅក្នុងមធ្យោបាយមួយ ដែលមិននាំពួកគេឆ្ពោះទៅរកស្ថានភាពប៉ះពាល់សុខភាពនិងគ្មានសុវត្ថិភាព។ BSIC បដិសេធការងារដែលគិតតែពីកម្រៃជើងសារមួយគត់ប៉ុណ្ណោះនោះ។

## 2- រចនាសម្ព័ន្ធការងារ

បុគ្គលិកផ្សព្វផ្សាយស្រាបៀរ នឹងត្រូវប្រាប់ឱ្យដឹងច្បាស់លាស់ថាតើនរណាទៅដែលជាអ្នកគ្រប់គ្រងរបស់ពួកគេ ហើយនិងប្រាប់ថា យើងមាននីតិវិធីមួយ សម្រាប់ពួកគេសំដែងពីទុក្ខកង្វល់ណាមួយដែលទាក់ទងនឹងការងាររបស់ពួកគេ។ នីតិវិធីនេះរួមមានផងដែរនូវការប្រើប្រាស់សម្រង់ទិន្នន័យមួយ ដែលមានកត់ត្រារាល់ទុក្ខកង្វល់ទាំងអស់នៅក្នុងនោះ។ នីតិវិធីនេះត្រូវមានទំនាក់ទំនងជាមួយបទដ្ឋានទី 6 ស្តីពីការបៀតបៀន។

## 3- ឯកសណ្ឋាន

បុគ្គលិកផ្សព្វផ្សាយស្រាបៀរដែលលក់ផលិតផលរបស់សមាជិក BSIC នឹងទទួលបាននូវឯកសណ្ឋានម៉ាកផលិតផល (ក្រុមហ៊ុន) ឬបន្ទះក្រណាត់ពាក់ឆៀងយ៉ាងច្បាស់មួយ ដែលមានបង្ហាញឈ្មោះផលិតផលផងដើម្បីអាចឱ្យគេមើលឃើញនិងស្គាល់ពួកគេយ៉ាងច្បាស់ ថាជាបុគ្គលិកដែលលក់ឬផ្សព្វផ្សាយស្រាបៀរ។ បុគ្គលិកផ្សព្វផ្សាយស្រាបៀរដែលចប់ភារកិច្ចមិនត្រូវពាក់ឯកសណ្ឋានឡើយ។ ឯកសណ្ឋានគួរតែមានភាពសមរម្យ ដោយយោលទៅតាមទំហំខ្នាត ដែលទទួលបានពីបុគ្គលិកទាំងនោះដោយផ្ទាល់។

## 4- មធ្យោបាយដឹកជញ្ជូន

និយោជករបស់បុគ្គលិកផ្សព្វផ្សាយស្រាបៀរ នឹងធានាដឹកជញ្ជូនពីកន្លែងធ្វើការទៅកាន់ផ្ទះរបស់បុគ្គលិកទាំងនោះ នៅពេលដែលពួកគេបញ្ចប់ការងារនៅតាមទីកន្លែងវេង១ខ្លួនរួចភ្លាម ដោយមានរួមបញ្ចូលទាំងបណ្តាខេត្តផងដែរ។ ធ្វើបែបនេះនឹងកាត់បន្ថយគ្រោះថ្នាក់នៃការបៀតបៀនលើបុគ្គលិកផ្សព្វផ្សាយស្រាបៀរ នៅក្រោយម៉ោងធ្វើការនៅតាមផ្លូវត្រលប់មកផ្ទះវិញ ឱ្យមានទាបជាអប្បបរមា។ បុគ្គលិកផ្សព្វផ្សាយស្រាបៀរត្រូវផ្តល់នូវមធ្យោបាយដឹកជញ្ជូនរបស់ក្រុមហ៊ុន និងត្រូវលើកទឹកចិត្តឱ្យប្រើប្រាស់មធ្យោបាយនេះ។

## 5- ការបណ្តុះបណ្តាល និង ការផ្តល់ព័ត៌មាន

សមាជិករបស់ BSIC ទាំងអស់នឹងផ្តល់នូវការបណ្តុះបណ្តាលតាមបទដ្ឋាននិងជំទូលំទូលាយមួយ ដែលជាផ្នែកមួយនៃការបណ្តុះបណ្តាលណែនាំការងាររបស់បុគ្គលិកផ្សព្វផ្សាយស្រាបៀរ។ ការបណ្តុះបណ្តាល នេះត្រូវរួមមាន : វិធីដោះស្រាយជាមួយអតិថិជនពិបាក១, ការប្រើប្រាស់គ្រឿងស្រវឹងនិងគ្រឿងញៀន, ការបៀតបៀននៅតាមកន្លែងធ្វើការ, ទំនាក់ទំនងរវាងបុរសនិងស្ត្រី , តួនាទី និងការទទួលខុសត្រូវផ្នែកភេទ , ជម្រើសនៃការគាំពារសុខភាព, សុខភាពផ្លូវភេទនិងការបន្តពូជ , វិធីការពារកំណើត ហើយនិងការអប់រំ និងការបង្ការស្តីពីរោគអេដស៍និងរោគឆ្លងដទៃទៀត។ ការបណ្តុះបណ្តាលបំពាក់បំប៉នឡើងវិញ គួរត្រូវរៀបចំឡើងយ៉ាងតិចម្តងក្នុងមួយឆ្នាំ។

## 6- ការបៀតបៀន

BSIC សូមប្រកាសនូវជំហរគ្មានការសណ្តោសសោះឡើយ ចំពោះការរំលោភបំពាននិងការបៀតបៀនផ្លូវភេទលើបុគ្គលិកផ្សព្វផ្សាយស្រាបៀរ។ សមាជិកទាំងអស់របស់ BSIC នឹងតាក់តែងនិងដាក់ឱ្យអនុវត្តនូវគោលការណ៍ប្រឆាំងការបៀតបៀនផ្លូវភេទចំពោះបុគ្គលិកក្រុមហ៊ុន ដោយកំណត់ថានេះគឺជាផ្នែកមួយនៃកិច្ចសន្យាការងារនិងក្រមស្តីពីការប្រព្រឹត្តរបស់គេ។ គោលការណ៍នេះនឹងត្រូវផ្សព្វផ្សាយយ៉ាងច្បាស់លាស់ចំពោះបុគ្គលិកទាំងអស់ ហើយនិងផ្តល់នូវការបណ្តុះបណ្តាលគ្រប់គ្រាន់ ដើម្បីគូសបញ្ជាក់ថា ការបៀតបៀនផ្លូវភេទនឹងមិនត្រូវអត់អោនឡើយ។ នឹងមានការដាក់ទណ្ឌកម្មក្នុងករណីមានការប្រព្រឹត្តល្មើស។ BSIC នឹងបញ្ជាក់ច្បាស់ពីការរំពឹងចង់បានរបស់ខ្លួនទៅកាន់ម្ចាស់ហាង ទាក់ទិននឹងការផ្តល់នូវបរិយាកាស ការងារសុខសាន្តចំពោះបុគ្គលិកផ្សព្វផ្សាយស្រាបៀរ ក្នុងនោះរួមមានទាំងការថ្លែងពីជំហរមិនអត់អោននោះផង។ សមាជិក BSIC ទាំងអស់នឹងរក្សានូវប្រព័ន្ធរាយការណ៍ពីការរំលោភបំពាននិងការបៀតបៀនដ៏សុក្រិតនិងមានលក្ខណៈបច្ចុប្បន្នភាព ព្រមទាំងចែករំលែកវានៅទូទាំង BSIC ទាំងមូល។ ត្រូវតែមានការកត់ត្រាជាដាច់ខាតនូវរាល់ករណីដែលត្រូវបានរាយការណ៍ទាំងអស់។ ក្នុងព្រឹត្តិការណ៍ដែលមានការបៀតបៀននោះ សមាជិក BSIC នឹងពិភាក្សាជាបឋមជាមួយម្ចាស់ហាងពីសកម្មភាពដែលត្រូវចាត់ធ្វើ។ ប្រសិនបើគ្មានសកម្មភាពណាមួយទេនោះ សមាជិក BSIC នឹងធ្វើសកម្មភាពដោយព្រមគ្នា ហើយទណ្ឌកម្មជាចុងក្រោយនោះ គឺការដកយកបុគ្គលិកផ្សព្វផ្សាយស្រាបៀរ (ដែលមកពីគ្រប់ម៉ាកស្រាបៀរដែលតំណាងដោយសមាជិក BSIC) ចេញពីកន្លែងដែលកើតមានការរំលោភបំពានផ្លូវកាយនិងផ្លូវភេទធ្ងន់ធ្ងរឬជាប់ជាបន្ត ព្រមទាំងនឹងចេញនូវសេចក្តីថ្លែងការណ៍សាធារណៈមួយសំដៅធានាឱ្យបានថា អ្នកទទួលផលប្រយោជន៍ផ្សេងៗទៀត ក៏នឹងត្រូវព្រមានផងដែរ។

## 7. គ្រឿងស្រវឹង

របនាសម្ព័ន្ធចាត់តាំងរបស់ឧស្សាហកម្មនេះ ទទួលស្គាល់នូវគ្រោះថ្នាក់ដែលបុគ្គលិកផ្សព្វផ្សាយស្រាបៀរជាច្រើនអាចត្រូវគាបសង្កត់ឱ្យផឹកស្រាបៀរ ដើម្បីគាំទ្រដល់ការលក់របស់គេនិងដើម្បីបំពេញចិត្តអតិថិជន។ ជាគោលការណ៍របស់ BSIC គឺថានៅក្នុងអំឡុងម៉ោងធ្វើការ បុគ្គលិកផ្សព្វផ្សាយស្រាបៀរមិនគប្បីអង្គុយឬផឹកជាមួយអតិថិជនឡើយ។ សមាជិក BSIC នឹងប្រាប់បុគ្គលិកផ្សព្វផ្សាយស្រាបៀរអំពីគោលការណ៍នេះ ហើយនិងបណ្តុះបណ្តាលបុគ្គលិកទាំងនោះពីរបៀបបដិសេធដោយមិនធ្វើឱ្យអាប់មុខអតិថិជន ហើយនិងពីជំហានដែលត្រូវធ្វើប្រសិនបើត្រូវគេបង្ខំឱ្យផឹក។

ភ្នំពេញ ថ្ងៃទី 20 ធ្នូ 2006

(ហត្ថលេខា)
**ក្រុមហ៊ុនផលិតស្រាបៀរអាស៊ី-ប៉ាស៊ីហ្វិក**
លោក C. Kidd

(ហត្ថលេខា)
**ក្រុមហ៊ុន Carlsberg**
លោក K. Hedeager Nielsen

(ហត្ថលេខា)
**រោងចក្រផលិតស្រាបៀរកម្ពុជា**
លោក L. Van Der Borght

(ហត្ថលេខា)
**ក្រុមហ៊ុន Guinness**
លោក L. Menuhin

(ហត្ថលេខា)
**ក្រុមហ៊ុន ខេមប្រ៊ូវ**
លោក S. Phommesy

(ហត្ថលេខា)
**ក្រុមហ៊ុន Heineken អន្តរជាតិ**
លោកស្រី K. van Craneburgh

ហត្ថលេខីខាងលើ បម្រើការឱ្យក្រុមហ៊ុនដូចខាងក្រោម :

| | | | |
|---|---|---|---|
| 1. | <u>ក្រុមហ៊ុនផលិតស្រាបៀរអាស៊ី-ប៉ាស៊ីហ្វិក</u><br>438 Alexander Road #16-10<br>Axander Point<br>SINGAPORE<br><u>លោក Chris Kidd</u><br>នាយកតំបន់ឥណ្ឌូចិន | 2. | <u>រោងចក្រផលិតស្រាបៀរកម្ពុជា</u><br>ភូមិបោះអង្កាញ់ ( ផ្លូវជាតិលេខ ១ ) ឃុំព្រែកឯង<br>ស្រុកកៀនស្វាយ ខេត្តកណ្ដាល<br>កម្ពុជា<br><u>លោក Lieven Van der Boght</u><br>អគ្គនាយក |
| 5. | <u>ក្រុមហ៊ុន ខេមប៊្រូវ</u><br>២១៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់<br>ខ័ណ្ឌចំការមន ភ្នំពេញ ១២៣០១<br>កម្ពុជា<br><u>លោក Saysana Phommesy</u><br>នាយកប្រតិបត្តិការជាន់ខ្ពស់ | 4. | <u>ក្រុមហ៊ុន Cambrew</u><br>100, Ny Carlsberg Vej<br>DK-1760 Copenhagen V<br>DENMARK<br><u>លោក Knud Hedeager Nielsen</u><br>នាយកទំនាក់ទំនងសាធារណៈ |
| 5. | <u>ក្រុមហ៊ុន Guinness</u><br>1 George Street<br>13th Floor, Ynit 01<br>Singapore 049145<br>SINGAPORE<br><u>លោក Lin Menulin</u><br>នាយកទទួលបន្ទុកគ្រឿងស្រវឹង<br>និងការទទួលខុសត្រូវ | 6. | <u>ក្រុមហ៊ុន Heineken អន្តរជាតិ</u><br>Tweede Weteringplantsoen 21<br>NL-1017 ZD<br>Amsterdam<br>THE NETHERLANDS<br><u>លោកស្រី Katinka van Cranenburgh</u><br>នាយកកម្មវិធីអន្តរជាតិ<br>កិច្ចការសុខភាព |